ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

L20230816026ITD4044

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធ ប្រចាំខែកក្កដា និងសម្រាប់រយៈពេល ៧ខែ ឆ្នាំ២០២៣ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ

ថ្ងៃពុធ ១៥ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាថ្ងៃពុធ ១៥ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែកក្កដា និងសម្រាប់រយៈពេល ៧ខែ ឆ្នាំ២០២៣ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្ត ដែលរៀបចំតាមប្រព័ន្ធអនឡាញ (Zoom Meeting) ក្រោមអធិបតីភាព ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពី ឯកឧត្តម-លោកជំទាវ-លោកអគ្គនាយករង លោកទីប្រឹក្សាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោក-លោកស្រីប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធទាំងអស់ ក្រោមចំណុះរបស់អគ្គនាយកដ្ឋានពន្ធដារ។

ចំពោះលទ្ធផលនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានបង្ហាញថាក្នុងខែកក្កដា ឆ្នាំ២០២៣ ចំណូលពន្ធ-អាករគ្រប់ប្រភេទដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារមានចំនួន **៩៧៣,៧៦ ប៊ីលានរៀល** (ប្រមាណជា **២៤០,៤៣ លានដុល្លារ**) ស្មើនឹង **៦,៧៣%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ សរុបរយៈពេល ៧ខែ ឆ្នាំ២០២៣ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន **៩ ៣៦៧,៤៤ ប៊ីលានរៀល** (ប្រមាណជា **២ ៣១២,៩៥ លានដុល្លារ**) ស្មើនឹង **៦៤,៧៦%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។




| ឆ្នាំ | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 (៧ខែ) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូល (ប៊ីលានរៀល) | 2,360.05 | 2,962.13 | 3,525.48 | 4,251.16 | 5,196.80 | 5,988.71 | 7,754.81 | 8,791.40 | 11,277.32 | 11,700.52 | 11,266.79 | 13,993.20 | 9,367.44 |
| ចំណូល (លានដុល្លារ) | $590.01 | $731.39 | $870.49 | $1,049.67 | $1,283.16 | $1,478.69 | $1,914.77 | $2,197.85 | $2,819.33 | $2,889.02 | $2,781.92 | $3,455.11 | $2,312.95 |
| ផែនការ (ប៊ីលានរៀល) | 2,655.37 | 2,944.43 | 3,463.61 | 3,975.16 | 4,659.50 | 5,686.26 | 6,863.30 | 7,693.50 | 9,153.63 | 11,543.31 | 9,084.42 | 11,419.13 | 14,465.39 |
| ផែនការ (លានដុល្លារ) | $663.84 | $736.11 | $865.90 | $993.79 | $1,164.88 | $1,421.56 | $1,715.83 | $1,923.38 | $2,288.41 | $2,850.20 | $2,243.07 | $2,819.54 | $3,571.70 |
| %ភាគរយនៃចំណូល | 88.88% | 100.60% | 101.80% | 106.94% | 111.53% | 105.32% | 113.00% | 114.27% | 123.20% | 101.36% | 124.02% | 122.54% | 64.76% |

© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

## ប្រសាសន៍សំខាន់ៗរបស់ឯកឧត្តម **គង់ វិបុល** ក្នុងកិច្ចប្រជុំ

- **ហានិភ័យដែលបណ្តាលពីភាពមិនប្រាកដប្រជា ការប្រែប្រួលបរិបទសេដ្ឋកិច្ចសកល ដែលបង្កដោយសារការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក និងវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន** ប៉ះពាល់ដល់បណ្តាប្រទេសដែលជាប្រភពទុនសម្រាប់វិនិយោគធំៗមកកម្ពុជា និងធ្វើឱ្យមានកំណើននៃអតិផរណា ដែលអាចជាហានិភ័យក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធឈានទៅប៉ះពាល់ដល់ចំណូលពន្ធឱ្យបានគ្រប់តាមផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ និងពិសេសមូលដ្ឋានក្នុងការព្យាករផែនការសម្រាប់ឆ្នាំបន្ទាប់
- ទោះជាយ៉ាងណាក្តី តាមរយៈស្ថានភាពនៃចំណូលពន្ធសម្រាប់រយៈពេល ៧ខែ ឆ្នាំ២០២៣អគ្គនាយកដ្ឋានពន្ធដាររំពឹងថាការអនុវត្តការងារគ្រប់គ្រងប្រមូលចំណូលពន្ធសម្រាប់ឆ្នាំ២០២៣ អាចនឹងសម្រេចបានគ្រប់តាមផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣
- កំណែទម្រង់និងទំនើបកម្មពន្ធដារចាប់តាំងពីឆ្នាំ២០១២ រហូតមក បានធ្វើឱ្យប្រព័ន្ធពន្ធដារមានភាពរឹងមាំ ដែល **រដ្ឋបាលកិច្ចល្អ គឺជាឆ្អឹងខ្នងនៃកំណែទម្រង់** ហើយថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ខិតខំប្រឹងប្រែង

ស្រុះស្រួលគ្នាអនុវត្តការងារប្រកបដោយស្មារតីបុរេសកម្ម និងកាន់តែសកម្មថែមទៀត ដើម្បីបន្តធានាបាននូវនិរន្តរភាពចំណូលពន្ធ និងបន្តចូលរួមអនុវត្តការងារកំណែទម្រង់និងទំនើបកម្មរដ្ឋបាលសារពើពន្ធ

- ផ្ដាំផ្ញើដល់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់ទាំងអស់នៃអគ្គនាយកដ្ឋានពន្ធដារត្រូវបន្តពង្រឹងការយកចិត្តទុក-ដាក់ខ្ពស់លើគុណភាពនៃការផ្ដល់សេវា និងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ខ្លួន ប្រកាន់ខ្ជាប់នូវអភិក្រមការងារ ៤ ប្រការ របស់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
- ការកត់សម្គាល់លើចំណូលតាមសកម្មភាពសំខាន់ៗមួយចំនួនមានការថយចុះសម្រាប់រយៈពេល ៧ខែ ឆ្នាំ២០២៣ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២២ ក្នុងនោះ កម្មន្តសាលភេសជ្ជៈឬផលិតភេសជ្ជៈ (ថយចុះ **១១,១៦%**) អចលនទ្រព្យ (ថយចុះ **៦,៧៧%**) ការសាងសង់ (ថយចុះ **២,៤៥%**) ហើយទន្ទឹមនឹងគ្នានោះ ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យក៏បាន (ថយចុះ **២៦,៥៦%**)
- ការប្រមូលបំណុលពន្ធមានការថយចុះសម្រាប់រយៈពេល ៧ខែ ឆ្នាំ២០២៣ ពោលគឺធ្លាក់ចុះ **២១,១២%** ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២
- បន្តពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធពីប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce) ដែលជាក់ស្ដែងក្នុងខែកក្កដា ឆ្នាំ២០២៣ ទទួលបាន **២៧,៥៨ ប៊ីលានរៀល** (ប្រមាណ **៦,៨១ លានដុល្លារ**) និងសម្រាប់រយៈពេល ៧ខែ ឆ្នាំ២០២៣ ទទួលបាន **១៨៦,៧៩ ប៊ីលានរៀល** (ប្រមាណ **៤៦,១២ លានដុល្លារ**)
- ពង្រឹងការបណ្ដុះបណ្ដាលអំពីការផ្ដល់សេវាល្អជូនដល់មន្ត្រីពន្ធដារ ជាពិសេសមន្ត្រីជួរមុខ ក្នុងគោលដៅរក្សាបាន និងធ្វើឱ្យប្រសើរឡើងនូវការផ្ដល់សេវាជូនអ្នកជាប់ពន្ធ និងបង្កើនភាពជឿជាក់ពីសំណាក់សាធារណជន និងអ្នកជាប់ពន្ធមកលើអគ្គនាយកដ្ឋានពន្ធដារ ដែលក្នុងរយៈពេល ៧ខែ ឆ្នាំ២០២៣ បានរៀបចំ **៥៣៩ លើក** មានអ្នកចូលរួមចំនួន **៦៣ ៨៨២ នាក់**
- បានពិគ្រោះយោបល់ជូនអ្នកជាប់ពន្ធតាម Call Center 1277, GDT Live Chat, Facebook, E-Mail, GDT News Channel និងពិគ្រោះយោបល់ដោយផ្ទាល់ សរុបចំនួន **៦២ ៣២៥ ករណី** ក្នុងរយៈពេល ៧ខែ ឆ្នាំ២០២៣

មុខងារស្នូល

២.១២- "ការផ្ដល់សេវាអ្នកជាប់ពន្ធ" - លទ្ធផលស្ដីពីការពិគ្រោះយោបល់ ប្រចាំឆ្នាំ២០២៣

**ចំនួនកើនឡើង ១ ៧២៣ ករណី គឺស្មើនឹងកើនឡើង ២,៨៤%**

| បរិយាយ | ០៧ខែ ២០២៣ | ០៧ខែ ២០២២ |
|---|---|---|
| ទូរស័ព្ទ (1277) | 37,251 | 37,380 |
| GDT Live Chat | 18,420 | 19,117 |
| បណ្ដាញសង្គម Facebook | 5,279 | 2,553 |
| កម្មវិធី "ពន្ធដារកម្ពុជា" | 29 | 28 |
| កម្មវិធី "រៀនអំពីពន្ធដារតាមអនឡាញ" | 27 | 26 |
| GDT News Channel | 1,319 | 1,498 |
| សរុបរួម | 62,325 | 60,602 |

សម្គាល់ ៖



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

- **ចំពោះវិស័យផលិតភេសជ្ជៈ (កម្មន្តសាលភេសជ្ជៈ)** បាននិងកំពុងបន្តចុះត្រួតពិនិត្យជាក់ស្តែងតាមរោងចក្រ ដើម្បីតាមដាន និងថែទាំបណ្តាញនិងឧបករណ៍វាស់ចំណុះស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរារបស់សហគ្រាសផលិតក្នុងស្រុក (Flowmeter) ហើយបានរកឃើញមានករណីគេចវេះនិងការបំពានការអនុវត្តកាតព្វកិច្ចបំពាក់ឧបករណ៍នេះ ដែលករណីនេះអគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងបន្តចាត់វិធានការពន្ធដារយ៉ាងម៉ឺងម៉ាត់ ដើម្បីធានាបាននូវតម្លាភាពនិងការប្រកួតប្រជែងដោយស្មើភាពសម្រាប់វិស័យនេះ។

## ជាទិសដៅសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២៣

## អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវវិធានការ និងជាយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖

- បន្តពង្រឹងការយកចិត្តទុកដាក់ខ្ពស់លើគុណភាពនៃការផ្តល់សេវា និងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារ ៤ ប្រការ របស់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីសារពើពន្ធថ្មី ជូនដល់អ្នកជាប់ពន្ធ សាធារណជន ព្រមទាំងក្រុមការងារវិស័យឯកជន និងអង្គការសមាគមនានាតាមគ្រប់រូបភាព ព្រមទាំងបន្តរៀបចំធ្វើបច្ចុប្បន្នភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារឱ្យស្របតាមច្បាប់ស្តីពីសារពើពន្ធថ្មី
- ផ្សព្វផ្សាយ និងអនុវត្តនូវការប្រើប្រាស់ឯកសណ្ឋានថ្មីរបស់មន្ត្រីរាជការពន្ធដារ ស្របតាមខ្លឹមសារអនុក្រឹត្យលេខ ២៥៣ សហវ.អនក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ ស្តីពីឯកសណ្ឋានថ្មីរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ
- បន្តការងារកែទម្រង់ធនធានមនុស្ស ដោយជំរុញនិងខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងត្រូវមានភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយផ្អែកលើទិដ្ឋភាពច្បាប់ក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធនិងការគ្រប់គ្រងប្រមូលចំណូលពន្ធ
- បន្តចុះត្រួតពិនិត្យជាក់ស្តែងតាមរោងចក្រ ដើម្បីតាមដាន និងថែទាំបណ្តាញនិងឧបករណ៍វាស់ចំណុះស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរារបស់សហគ្រាសផលិតក្នុងស្រុក (Flowmeter) ដើម្បីពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធ តម្លាភាព និងការប្រកួតប្រជែងដោយស្មើភាពក្នុងវិស័យផលិតភេសជ្ជៈ ដើម្បីធានាបាននូវនិរន្តរភាពចំណូលពន្ធដែលជាគុណប្រយោជន៍នៃថវិកាជាតិ ហើយនឹងចាត់វិធានការពន្ធដារយ៉ាងម៉ឺងម៉ាត់ ចំពោះករណីគេចវេះនិងការបំពានការអនុវត្តកាតព្វកិច្ច
- បន្តរៀបចំប្រព័ន្ធ និងយន្តការ**ដំឡើងឧបករណ៍តាមដាន GPS និង RFID** តាមរថយន្តដឹកជញ្ជូនប្រេងឥន្ធនៈ និងគ្រឿងសំណង់ និងតាមស្ថានីយ ក្នុងគោលដៅបន្តពង្រឹងការគ្រប់គ្រងប្រមូលពន្ធ តម្លាភាព និងការប្រកួតប្រជែងដោយស្មើភាពក្នុងវិស័យទាំងនេះ
- បន្តពង្រឹងការផ្តល់សេវាពិគ្រោះយោបល់ និងការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ តាមគ្រប់រូបភាពជាពិសេសការផ្តល់សេវាពិគ្រោះយោបល់តាមរយៈទូរស័ព្ទ (Call Center-1277) និងការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" (GDT Facebook Live) ដើម្បីពន្យល់និងដោះស្រាយការលំបាកនិងចម្ងល់របស់ប្រជាពលរដ្ឋ

- បន្តអនុវត្តវិធានការទារនិងតឹងទារបំណុលពន្ធតាមនីតិវិធីជាធរមាន ចំពោះសហគ្រាសដែលជំពាក់បំណុលពន្ធ ហើយមិនបានចូលខ្លួនមកទូទាត់ឬដោះស្រាយឱ្យបានត្រឹមត្រូវ
- បន្តពង្រឹងការងារចុះបញ្ជីពន្ធដារនិងធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ និងបន្តសហការចូលរួមកែលម្អ និងជំរុញការងារចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX) ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពគ្រប់ជ្រុងជ្រោយ
- បន្តពង្រឹងការចុះបញ្ជីសហគ្រាសថ្មីដោយសហការជាមួយក្រសួងពាណិជ្ជកម្ម ព្រមទាំងពង្រឹងប្រសិទ្ធភាពការងារ និងតួនាទីរបស់ភ្នាក់ងារចុះបញ្ជីពាណិជ្ជកម្ម
- បន្តផ្សព្វផ្សាយនិងពង្រឹងការអនុវត្តវិធានវិក្កយបត្រក្នុងចំណោមអ្នកជាប់ពន្ធ និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw) ឱ្យមានការចូលរួមបន្ថែមទៀតពីសាធារណជន ដើម្បីធានាបាននូវប្រសិទ្ធភាពនិងតម្លាភាពក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធអាករនានា
- បន្តពង្រឹងការគ្រប់គ្រងសហគ្រាសស្នើសុំផ្អាកបណ្ដោះអាសន្ន ឬស្នើសុំបើកដំណើរការឡើងវិញ និង/ឬ ព្យួរទុកឬបើកដំណើរការវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម
- បន្តពង្រឹងនិងយកចិត្តទុកដាក់ចំពោះការស្នើសុំបិទសហគ្រាសជាស្ថាពរ និងពង្រឹងលើការងារសវនកម្មសម្រាប់សហគ្រាសស្នើសុំបិទ
- បន្តចូលរួមក្នុងក្របខ័ណ្ឌការងារប្រឆាំងនឹងបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ជាមួយគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ) និងអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (អ.អ.ផ)
- **បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងកម្មវិធីប្រកបដោយស្មារតីបុរេសកម្ម** តាមរយៈការអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាពប្រព័ន្ធនិងកម្មវិធីថ្មីៗ បន្តវិនិយោគ និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងពង្រឹងសមត្ថភាពមុខងារវិភាគទិន្នន័យបន្ថែមទៀត ដើម្បីបន្តជំរុញបង្កើនកម្រិតអនុលោមភាពសារពើពន្ធ ដោយធ្វើយ៉ាងណាឱ្យងាយស្រួលក្នុងការបំពេញកាតព្វកិច្ចពន្ធប៉ុន្តែពិបាកក្នុងការគេចវេះតាមរយៈការបន្តអភិវឌ្ឍបន្ថែមនូវមុខងារមួយចំនួន តាមធាតុចូលដែលទទួលបានពីអ្នកប្រើប្រាស់ពីគ្រប់មជ្ឈដ្ឋាន ដើម្បីឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយនិងងាយស្រួលក្នុងការប្រើប្រាស់
- បន្តអនុវត្តវិធានការបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់បន្តគ្រប់គ្រងផលប៉ះពាល់ និងគាំទ្រការងើបឡើងវិញនៃវិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបន្តកាត់បន្ថយផលប៉ះពាល់មកលើស្ថានភាពសង្គម-សេដ្ឋកិច្ច ព្រមទាំងបន្តជួយទ្រទ្រង់ និងស្តារអាជីវកម្ម និងធុរកិច្ចឱ្យងើបឡើងវិញ
- អនុវត្តនូវវិធានការរបស់រាជរដ្ឋាភិបាលសម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យសំណង់និងអចលនទ្រព្យ ដើម្បីរក្សាស្ថិរភាពនៃវិស័យសំណង់ និងអចលនទ្រព្យ ដែលត្រូវបានចាត់ទុកជាវិស័យអាទិភាពមួយគាំទ្រដល់កំណើនសេដ្ឋកិច្ចជារួម

- បន្តអនុវត្តវិធានការចាំបាច់នានាដូចមានកំណត់ក្នុងសារាចរណែនាំស្ដីពី ការអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ និងបន្តអនុវត្តដោយការយកចិត្តទុកដាក់នូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣។

ជាកិច្ចបញ្ចប់ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានវាយតម្លៃខ្ពស់ និងថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់នៅតាមអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដែលបាន និងកំពុងចូលរួមយ៉ាងសកម្មក្នុងការខិតខំប្រឹងប្រែងប្រមូលចំណូល ដោយទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ដែលជាជោគជ័យនិងជាសមិទ្ធផលរួមរបស់អគ្គនាយកដ្ឋានពន្ធដារទាំងមូល។ ជាមួយគ្នានេះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីសូមជូនពរថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារទាំងអស់ជួបតែវិបុលសុខ និងសមប្រកបនឹងពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ